**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ៖ ៧៤៤/២២ ល.ក.ជ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ជម្រាបជូន

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត**
**និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ**

**<u>កម្មវត្ថុ</u>៖** អញ្ជើញ **ឯកឧត្តម លោកជំទាវ** ដើម្បីចូលរួមកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ អភិបាល** ជ្រាបថា៖ ជារៀងរាល់ឆ្នាំព្រះរាជាណាចក្រកម្ពុជា បានកំណត់យកថ្ងៃទី១២ ខែធ្នូ ជាថ្ងៃប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស ដើម្បីជាយុទ្ធនាការរួមគ្នា បង្កើតនូវប្រព័ន្ធសុវត្ថិភាព សម្រាប់ការពារប្រជាពលរដ្ឋឲ្យរួចផុតពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាធនធានដ៏មានសក្តានុពលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងទស្សនវិស័យព្រះរាជាណាចក្រកម្ពុជា មានសន្តិភាព សមភាព យុត្តិធម៌ និងការអភិវឌ្ឍ ដោយការពារប្រជាពលរដ្ឋ យ៉ាងពេញទំហឹងពីរាល់ទម្រង់ នៃអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា ។

កម្មវិធីនឹងប្រារព្ធធ្វើនៅថ្ងៃចន្ទ ៤រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ១៣:៣០ នាទីរសៀល នៅសាលមហោស្រពកោះពេជ្រ។
(ជូនភ្ជាប់ជាមួយនូវ៖ កម្មវិធី ០១ច្បាប់)

<u>បញ្ជាក់</u>៖ សម្លៀកបំពាក់ (អាវយឺតទិវាជាតិ ១២ធ្នូ)

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ អភិបាល** មេត្តាអញ្ជើញចូលរួមតាមការគួរ ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ៕

*ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*
*រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២*

**ជ.ប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ**
**អនុប្រធានអចិន្ត្រៃយ៍**

[signature]

**ជូ_ប៊ុនអេង**

*<u>បញ្ជាក់</u>៖ សូមមេត្តាផ្តល់ព័ត៌មានត្រឡប់*
*ដើម្បីបញ្ជាក់អំពីវត្តមាននៃការចូលរួមឲ្យបានមុន*
*ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២*
*-សូមទំនាក់ទំនងតាមរយៈទូរស័ព្ទ*
*ឧ.ទោ ហាង ជីវ័ន្ត-០៧៧ ៧០១ ២៣៨*
*ឧ.ទោ ចោង វុទ្ធី -០១២ ៩៥៨ ២១០*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

លេខៈ ១៩៣ / សជ

# សូមគោរពជូន

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

លេខៈ 3005
ថ្ងៃ 06.10.22

**កម្មវត្ថុ៖** សូមគោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ ដើម្បីរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ។

**យោង៖** ផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជំហានទី០៣ ឆ្នាំ ២០១៩-២០២៣ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា៖ ជារៀងរាល់ឆ្នាំព្រះរាជាណាចក្រកម្ពុជា បានកំណត់យកថ្ងៃទី១២ ខែធ្នូ ជាថ្ងៃប្រារព្ធទិវាជាតិប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីជាយុទ្ធនាការរួមគ្នា បង្កើតនូវប្រព័ន្ធសុវត្ថិភាព សម្រាប់ការពារប្រជាពលរដ្ឋឲ្យរួចផុតពីភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលជាធនធានដ៏មានសក្តានុពលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងទស្សនវិស័យ ព្រះរាជាណាចក្រកម្ពុជា មានសន្តិភាព សមភាព យុត្តិធម៌ និងការអភិវឌ្ឍ ដោយការពារប្រជាពលរដ្ឋ យ៉ាងពេញទំហឹងពីរាល់ទម្រង់នៃអំពើជួញដូរ និងការធ្វើអាជីវកម្មលើមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា ។

នៅឆ្នាំ ២០២០-២០២១ ដោយសារការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ការប្រារព្ធមិទ្ទិញសម្រាប់ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ត្រូវបានផ្អាក ដោយគ្រាន់តែរៀបចំជាបទយកការណ៍ ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងបរិបទ កូវីដ-១៩ និងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គមតែប៉ុណ្ណោះ ។

ជាថ្មីម្តងទៀត សម្រាប់ឆ្នាំ២០២២ នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងរៀបចំប្រារព្ធមិទ្ទិញទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឡើងវិញ ដែលនឹងប្រារព្ធធ្វើនៅសាលមហោស្រព កោះពេជ្រ ដោយមានអ្នកចូលរួមប្រមាណ ៣០០០ អង្គ/នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម** មេត្តាពិនិត្យសម្រេច និងគោរពសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ ៕

ថ្ងៃ........................ ខែ........................ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី........ ខែ........ ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កម្មវិធី

## ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ ២០២២
## ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងលោកជំទាវ

ថ្ងៃចន្ទ ៤រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២
នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ

| | | |
|---|---|---|
| ម៉ោង១៣:៣០ នាទីរសៀល | ៖ | ជួបជុំសមាជិក សមាជិកា នៃអង្គមិទ្ទិញ |
| ម៉ោង១៤:៣០ នាទីរសៀល | ៖ | ភ្ញៀវកិត្តិយសអញ្ជើញមកដល់ |
| ម៉ោង១៤:៤៥ នាទីរសៀល | ៖ | គណៈអធិបតីអញ្ជើញមកដល់ |
| ម៉ោង១៥:០០ នាទីរសៀល | ៖ | **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងលោកជំទាវ** អញ្ជើញដល់ |

## ចាប់ផ្តើមកម្មវិធី

- គោរពភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសហេតុ គោលបំណងនៃអង្គមិទ្ទិញ និងដំណើរការនៃកម្មវិធី
- មតិស្វាគមន៍ដោយ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
- ខ្សែវីដេអូបទយកការណ៍ ស្តីពីស្ថានភាពនៃអំពើជួញដូរមនុស្ស និងការឆ្លើយតបរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា
- ការសម្តែងសិល្បៈដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- មតិសំណេះសំណាល និងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

## ចប់កម្មវិធី

*(សូមពាក់អាវដែលក្រុមការងារផ្ញើជូន។ សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធី ក្នុងករណីចាំបាច់)*